ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសជប៉ុន

# សេចក្តីប្រកាសព័ត៌មាន

## ឯកអគ្គរាជទូតកម្ពុជា ពិភាក្សាអំពីកិច្ចសហប្រតិបត្តិការ ជាមួយប្រធានសមាគមជប៉ុន-កម្ពុជា

នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម ជុំ សុន្ទរី ឯកអគ្គរាជទូតតែងតាំងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុន បានទទួលជួបពិភាក្សាការងារជាមួយ ឯកឧត្តម តាកាហាស៊ី ហ៊្វូមីអាគី ប្រធានសមាគមជប៉ុន-កម្ពុជា (JCA) និងជាអតីតឯកអគ្គរដ្ឋទូតជប៉ុនប្រចាំប្រទេសកម្ពុជា រួមជាមួយសមាជិកនៃសមាគម។ ជំនួបនេះ បានប្រព្រឹត្តទៅក្នុងបរិយាកាសស្និទ្ធស្នាល និងបានឆ្លុះបញ្ចាំងពីមិត្តភាពដ៏យូរអង្វែង និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងកម្ពុជានិងជប៉ុន។

នៅក្នុងជំនួប ឯកឧត្តមឯកអគ្គរាជទូត បានសម្តែងការកោតសរសើរយ៉ាងខ្លាំងចំពោះភាពដឹកនាំ និងការចូលរួមចំណែកយ៉ាងយូរអង្វែងរបស់ឯកឧត្តម តាកាហាស៊ី នៅក្នុងការពង្រឹងទំនាក់ទំនងកម្ពុជា-ជប៉ុន ទាំងក្នុងពេលដែលឯកឧត្តមកាន់តំណែងជាឯកអគ្គរដ្ឋទូតជប៉ុនប្រចាំប្រទេសកម្ពុជា និងទាំងក្នុងការបន្តចូលរួមកិច្ចការងារពាក់ព័ន្ធបន្ទាប់ពីនោះ។ ឯកឧត្តមឯកអគ្គរាជទូត បានសរសើរពីតួនាទីជាប្រវត្តិសាស្ត្រ និងជាអ្នកត្រួសត្រាយផ្លូវរបស់សមាគមជប៉ុន-កម្ពុជា ចាប់តាំងពីការបង្កើតឡើងក្នុងឆ្នាំ១៩៦៣មក ក្នុងការលើកកម្ពស់ការយោគយល់គ្នាទៅវិញទៅមក ចំណងមិត្តភាពរវាងប្រជាជននិងប្រជាជន និងកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច វប្បធម៌ អប់រំ និងសង្គម រួមទាំងក្នុងអំឡុងពេលដ៏លំបាកក្នុងប្រវត្តិសាស្ត្រកម្ពុជាផងដែរ។

ភាគីទាំងពីរ បានផ្លាស់ប្តូរទស្សនៈលើការបន្តពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត ក្រោមភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយកម្ពុជា-ជប៉ុន។ ក្នុងនោះ ឯកឧត្តមឯកអគ្គរាជទូត បានសរសើរពីសកម្មភាពដ៏មានតម្លៃរបស់សមាគម រួមមាន ការជំរុញពាណិជ្ជកម្មនិងវិនិយោគ ការផ្លាស់ប្តូរការសិក្សានិងយុវជន កិច្ចសហប្រតិបត្តិការវប្បធម៌ ការផ្សព្វផ្សាយព័ត៌មានពិតអំពីកម្ពុជា និងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជា។ ឯកឧត្តម បានគូសបញ្ជាក់ពីសារៈសំខាន់នៃការទូតTrack-2 និងការចូលរួមពីប្រជាជននិងប្រជាជន ក្នុងការបំពេញបន្ថែមនូវទំនាក់ទំនងទ្វេភាគីផ្លូវការនៃប្រទេសទាំងពីរ។

នៅចុងបញ្ចប់ ឯកឧត្តមឯកអគ្គរាជទូត បានបញ្ជាក់ជាថ្មីអំពីការត្រៀមខ្លួនរួចជាស្រេចរបស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងតូក្យូ ក្នុងការធ្វើការយ៉ាងជិតស្និទ្ធជាមួយសមាគមជប៉ុន-កម្ពុជា ដើម្បីគាំទ្រគំនិតផ្តួចផ្តើមនានា និងដើម្បីបន្តពង្រឹងបន្ថែមនូវចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមករវាងកម្ពុជានិងជប៉ុន។

តូក្យូ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦

8-6-9 AKASAKA, MINATO-KU, TOKYO 107-0052
Tel : +81 3-5412-8521 Fax: +81 3-5412-8526
Email: camemb.jpn@mfaic.gov.kh